THE SCHOOL DISTRICT OF PHILADELPHIA

ការិយាល័យ អគ្គនាយក
440 North Broad Street
Philadelphia, PA 1913

**William R. Hite, Jr., Ed.D.**
អគ្គនាយក

ថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០២០

ជូនចំពោះ ក្រុមគ្រួសារ របស់ក្រសួងអប់រំ ជាទីគោរព៖

ខ្ញុំសង្ឃឹមថា លោកអ្នក និង ក្រុមគ្រួសាររបស់លោកអ្នក មានសុខភាពល្អ និង មានសុវត្ថិភាព នៅពេលដែលជម្ងឺរាតត្បាតនៃមេរោគ ខូវីដ-១៩ កំពុងតែរីករាលដាល។ យើងបានរៀបចំផែនការដើម្បីផ្តល់ឱកាសឱ្យសិស្សទាំងអស់អាចសិក្សាតាមកុំព្យូទ័រ ក្នុងករណីដែលសាលារបស់យើងបន្តបិទរយៈពេលវែង។ ផែនការនេះ ផ្តល់កុំព្យូទ័រក្រូមប៊ុក (Chromebook) ដល់សិស្សរបស់ក្រសួងណាដែលត្រូវការវា ដើម្បីសិក្សានៅផ្ទះ និង បង្កើតឯកសារតាមកុំព្យូទ័រ ដើម្បី រក្សា និង រៀន ពីចំណេះដឹង ដោយមានជំនួយពីគ្រូ។

នៅថ្ងៃព្រហស្បតិ៍ ទី ២៦ ខែមីនា គណៈកម្មការអប់រំបានជំរុញផែនការនេះ ដោយអនុម័តឱ្យចំណាយទឹកប្រាក់ចំនួន ១១ លានដុល្លារ សម្រាប់ទិញកុំព្យូទ័រក្រូមប៊ុកថ្មី រហូតដល់ទៅ ៥០.០០០ គ្រឿង។ ក្រសួងនឹងកំណត់ជាក់លាក់នូវចំនួនឧបករណ៍ថ្មីដែលត្រូវទិញ នៅពេលការិយាល័យកណ្តាលធ្វើការជាមួយសាលានីមួយៗ ដើម្បីកំណត់ថា តើកុំព្យូទ័រក្រូមប៊ុកប៉ុន្មានហើយដែលពួកគេមាននៅក្នុងសាលារបស់ពួកគេបច្ចុប្បន្ននេះ សម្រាប់ចែកចាយ និង សិស្សរបស់ពួកគេដែលត្រូវការកុំព្យូទ័រ មានចំនួនប៉ុន្មាន។

ក្រសួងអប់រំកំពុងធ្វើការជាមួយទីក្រុងភីឡាដែលហ្វ្យ៉ា ដើម្បីបង្កើតបញ្ជីជម្រើសអ៊ីនធ័រណិតដែលមានតម្លៃថោក ឬ អាចប្រើវ៉ាយហ្វាយ (WiFi) តាមទូរស័ព្ទដៃដោយឥតគិតថ្លៃ នៅទូទាំងក្រុង។ បញ្ជីនេះនឹងមាននៅក្នុង វិបសៃរបស់ក្រសួង និង វិបសៃរបស់ទីក្រុងហ្វីឡាដែលហ្វ្យ៉ា ឱ្យទាន់សប្តាហ៍នៃថ្ងៃទី ៦ ខែមេសា។

សម្រាប់ក្រុមគ្រួសារដែលរស់នៅតាមតំបន់នានានៃទីក្រុង ដែលមានប្រព័ន្ធ វ៉ាយហ្វាយ អ៊ិចហ្វីនីធី (Xfinity WiFi) ក្រុមហ៊ុន ខមខាស្ត នឹងផ្តល់ វ៉ាយហ្វាយ អ៊ិចហ្វីនីធី ដោយឥតគិតថ្លៃសម្រាប់អ្នករាល់គ្នា - រួមទាំងអ្នកដែលមិនមែនជាអតិថិជនរបស់អ៊ីនធ័រណិតអ៊ិចហ្វីនីធី។ ដើម្បីមើលផែនទីនៃចំណុច វ៉ាយហ្វាយ អ៊ិចហ្វីនីធី សូមចូលមើលវិបសៃ www.xfinity.com/wifi។

នេះជាផែនការរួម និង អ្វីៗដែលលោកអ្នកអាចរំពឹងទុក៖

ថ្ងៃទី ២៣-២៧ ខែមីនា ឆ្នាំ ២០២០

- នាយកសាលាប៉ាន់ប្រមាណចំនួនសិស្សនៅក្នុងសាលារបស់ពួកគាត់ដែលគ្មានកុំព្យូទ័រនៅផ្ទះ និងកំណត់ថាបុគ្គលិកណាដែលអាចជួយ រៀបចំ និង ចែកចាយ កុំព្យូទ័រក្រូមប៊ុក នៅសាលា។

ថ្ងៃទី ៣០ ខែមីនា ដល់ថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០២០

- ក្រុមរបស់សាលា រៀបចំ កុំព្យូទ័រក្រូមប៊ុក នៅសាលារបស់ពួកគាត់ សម្រាប់ចែកចាយ។
- បានបង្កើតឯកសារតាមកុំព្យូទ័រ។ គ្រូទទួលការបណ្តុះបណ្តាលតាមអ៊ីនធ័រណិត អំពីវិធីប្រើប្រភពជំនួយតាមកុំព្យូទ័រ ដើម្បីជួយដល់សិស្សានុសិស្សទាំងអស់ដែលពួកគាត់បង្រៀន។

<u>ថ្ងៃទី ៦-៨ ខែមេសា ឆ្នាំ ២០២០</u>

- គេនឹងជម្រាបឱ្យក្រុមគ្រួសារដឹងអំពី ថ្ងៃ និង ម៉ោង ទៅយកកុំព្យូទ័រ តាមមធ្យោបាយជាច្រើនដូចជា ការហៅទូរស័ព្ទ និង ផ្ញើសារតាមទូរស័ព្ទដៃ។

<u>ថ្ងៃទី ១៣-១៧ ខែមេសា ឆ្នាំ ២០២០</u>

- ចែក កុំព្យូទ័រក្រូមប៊ុក ដល់ សិស្ស/ក្រុមគ្រួសារ នៅតាមសាលារៀន ដោយការប្រើវិធីនៅឆ្ងាយពីគ្នា និងវិធីរក្សាសុវត្ថិភាព ដទៃទៀត យ៉ាងមឿងម៉ាត់។ ជំនួយរក្សាសុវត្ថិភាពក្នុងការចែក កុំព្យូទ័រក្រូមប៊ុក ផ្តល់ឱ្យដោយបុគ្គលិក ក្រសួងអប់រំ ទីក្រុងហ្វីឡាដែលហ្វ្យា និង ការិយាល័យផ្នែកសន្តិសុខសាលារៀន។
- គ្រូចាប់ផ្តើមប្រើវិធីសាស្ត្រតាមកុំព្យូទ័រដើម្បីផ្តល់ការបង្ហាត់បង្រៀន តាមការជ្រើសរើស មិនដាក់ពិន្ទុ និង តាមអ៊ីនធ័រណិតដល់សិស្សានុសិស្ស។ ឯកសារទាំងនេះអាច ពង្រឹងចំណេះដឹង ផ្តល់នូវឱកាសសិក្សាបន្ថែម និង បញ្ចូលឯកសារថ្មីៗ ទៅតាមលក្ខណៈសមស្រប។ គ្រូក៏អាចប្រើសកម្មភាពផ្ទាល់ខ្លួនដើម្បីចូលរួមជាមួយសិស្សានុសិស្សរបស់ពួកគាត់។
- សិស្សានុសិស្ស និង ក្រុមគ្រួសារ ក៏អាចទទួលបានការជួយបង្រៀនបន្ថែមតាមអ៊ីនធ័រណិត តាមការជ្រើសរើស សម្រាប់ ថ្នាក់រៀនហ្គូហ្គោល និង វិធីផ្សេងៗទៀតរបស់ហ្គូហ្គោល។

នេះគឺជាវិធីថ្មីសម្រាប់យើងទាំងអស់គ្នា។ នៅមានការងារជាច្រើនដែលយើងត្រូវធ្វើដើម្បី បញ្ចប់ និង អនុវត្ត ផែនការទាំងនេះ។ យើងទាំងអស់គ្នាប្តេជ្ញាថា សិស្សានុសិស្សរបស់យើងអាចបន្តការរៀនសូត្រក្នុងពេលដែលយើងមិនធ្លាប់ជួបប្រទះ ក្នុងខណៈពេលដែលយើងធ្វើការដើម្បីរក្សា សុវត្ថិភាព និង សុខភាព របស់មនុស្សគ្រប់គ្នា។ យើងនឹងធ្វើការងារនេះដោយយកចិត្តទុកដាក់ និង ដោយភាពបន្ទាន់ ដែល សិស្សានុសិស្ស និង ក្រុមគ្រួសារ របស់យើងគប្បីនឹងទទួលបាន។

ដោយសេចក្តីរាប់អាន

William R. Hite Jr., Ed.D.
អគ្គនាយក
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា